# មេរៀនទី ១២១ ៖ ព្រះយេស៊ូវមានបន្ទូលទៅកាន់ស្ត្រីសាសន៍សាម៉ារី

យ៉ូហាន ៤៖៥-៤២

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/ne4zvlZnCyM

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/_zw_jxZN46A

**គោលបំណង៖** ព្រះយេស៊ូវជាទឹករស់បំពេញដល់ជីវិតយើង។

**ខគម្ពីរចងចាំ៖** យ៉ូហាន ៤៖១៤ក *"តែអ្នកណាដែលផឹកទឹកខ្ញុំឲ្យ នោះនឹងមិនស្រេកទៀតឡើយ។"*

**ចម្រៀង** ( *យូធូបលីង* )៖

១. នៅរស់ https://youtu.be/NGQXTg3Uogg

២.មានទន្លេជីវិត https://youtu.be/AP6fwLxUqK0

៣. ខ្ញុំដឹងថា https://youtu.be/ywt-KvGIQcE

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត «បំពេញកែវ»




សម្ភារៈដែលត្រូវការ៖ កែវ៤ ទុយោ២ និងតុ

១. ចែកកុមារជា២ក្រុម ហើយហើយពួកគេឈរជាជួរ

២. ចាក់ទឹកក្នុងកែវ ២ ហើយកែវ ២ទៀតទុកឲ្យនៅទទេហើយដាក់ក្បែរគ្នានោះ និងទុយោ២ផងដែរ

៣. នៅពេលដែលគ្រូនិយាយថា ១ ២ ៣ កុមារទីមួយនៃក្រុមទាំងពីរត្រូវរត់ទៅកាន់តុ ហើយប្រើទុយោដើម្បីបញ្ជូនទឹក ទៅដាក់ក្នុងកែវទទេ។ ពួកគេគឺអាចប្រើបានតែដៃម្ខាងប៉ុនណ្ណោះ។ ពួកគេអាចប្រើទុយោដាក់ចូលទៅក្នុងកែវដែលមានទឹក ហើយចង្អុលដៃរបស់ពួកគេបិតទុយោផ្នែកខាងលើ ហើយបន្ទាប់មកយកទឹកនោះទៅដាក់ក្នុងកែវទទេ។

៤. កុមារម្នាក់អាចប្រើពេល ៣០ វិនាទីក្នុងការជញ្ជូនទឹកដាក់បំពេញកែវ

៥. សូមលេងល្បែងនេះរហូតដល់កុមារបានលេងគ្រប់ៗគ្នា។

៦. ក្រុមណាដែលអាចជញ្ជូនទឹកដាក់ចូលទៅក្នុងកែវបានច្រើនជាងក្រុមនោះជា អ្នកឈ្នះ

៧. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះយេស៊ូវគឺជាទឹករស់ ដែលតែងតែបំពេញនូវសេចក្ដីត្រូវការរបស់យើង។

## ៤. ការណែនាំមេរៀន

តើអ្នកនឹងទៅជាយ៉ាងមិចបើអ្នកចង់ញាំតែម្ហូបតែអត់ចង់ញាំទឹក? តើអ្នកដឹងទេថា មនុស្សនឹងស្លាប់ប្រសិនបើពួកគេមិនញាំទឹក? ទឹកបំពេញចិត្តយើងពេលយើងស្រេកទឹក។ គ្រប់ភាវៈមានជីវិតទាំងអស់ត្រូវការទឹកដើម្បីរស់។ ថ្ងៃនេះយើងនឹងរៀនថាព្រះយេស៊ូវជាទឹករស់។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

រឿងនៅក្នុងព្រះគម្ពីររបស់យើងថ្ងៃនេះ គឺនិយាយអំពីស្ត្រីសាសន៍សាម៉ារីម្នាក់ ដែលជឿលើព្រះ ប៉ុន្តែនាងមិន

ស្គាល់ព្រះយេស៊ូវទេ។ ថ្ងៃមួយ ព្រះយេស៊ូវមានការហត់នឿយ និងស្រេកទឹក ពេលទ្រង់កំពុង ធ្វើដំណើរឆ្លងកាត់ស្រុកសាម៉ារី។ ព្រះអង្គអង្គុយនៅមាត់អណ្ដូង ខណៈពួកសិស្សទៅរកអាហារ។ ពេលនោះមានស្ត្រីម្នាក់ មកដងទឹកពីអណ្ដូង ហើយព្រះយេស៊ូវបានសុំទឹកនាងសោយ។ ដូច្នេះនាងក៏បានថ្វាយទឹកខ្លះដល់ទ្រង់។

បន្ទាប់មក ព្រះយេស៊ូវប្រាប់នាងថា ទ្រង់ចង់ប្រទានទឹករស់ដល់នាង។ ព្រះអង្គកំពុងមានបន្ទូលអំពីខ្លួនទ្រង់។ ទ្រង់មានន័យថា ទ្រង់ចង់បំពេញអ្វីដែលល្អដល់នាង ដូចជាសេចក្ដីស្រឡាញ់ សន្តិភាព និងការអត់ទោសរបស់ព្រះយេស៊ូវ។ ព្រះយេស៊ូវបានដឹងថាមានតែព្រះអង្គប៉ុណ្ណោះ ដែលអាចបំពេញចិត្តនាងបាន។ ព្រះអង្គចង់ផ្ដល់ឱ្យនាងនូវជីវិតដ៏អស់កល្បជានិច្ច និងសុភមង្គលពិតប្រាកដ ដែលអាចរកបានដោយការជឿលើព្រះយេស៊ូវប៉ុណ្ណោះ។

**យ៉ូហាន ១៤:១៣-១៤** "ព្រះយេស៊ូវមានព្រះបន្ទូលឆ្លើយថា អស់អ្នកណាដែលផឹកទឹកនេះ នឹងត្រូវស្រេកទៀត តែអ្នកណាដែលផឹកទឹកខ្ញុំឲ្យ នោះនឹងមិនស្រេកទៀតឡើយ ទឹកដែលខ្ញុំឲ្យ នឹងត្រឡប់ជារន្ធទឹកនៅក្នុងអ្នកនោះ ដែលផុសឡើងដល់ទៅបានជីវិតអស់កល្បជានិច្ច។"

ព្រះយេស៊ូវបានប្រាប់ស្ត្រីសាសន៍សាម៉ារីអំពីរឿងផ្ទាល់ខ្លួននាង ជារឿងដែលទ្រង់មិនអាចដឹងបានលុះត្រាតែទ្រង់ជាព្រះ។ ព្រះអង្គដឹងថានាងឯកោ ហើយស្វែងរកស្នេហាមិនបានសមដូចបំណង។ ព្រះយេស៊ូវចង់ប្រទានពរ ឲ្យនាងនូវអ្វីដែលនាងមិនអាចទទួលបានសម្រាប់ខ្លួននាង។

ព្រះយេស៊ូវចង់បំពេញចិត្តយើង។ តើអ្នកត្រូវការអ្វីនៅថ្ងៃនេះ? តើអ្នកឯកាមែនទេ? ខឹងនឹងនរណាម្នាក់មែនទេ? តើអ្នកត្រូវការជំនួយក្នុងការអភ័យទោសដល់នរណាម្នាក់ទេ? ប្រហែលជាអ្នកត្រូវអត់ទោសឱ្យខ្លួនឯង។ តើអ្នកត្រូវការជំនួយក្នុងការស្ដាប់បង្គាប់ឪពុកម្ដាយ ឬមានចិត្តសប្បុរស ឬអត់ធ្មត់ឬទេ? តើថ្ងៃនេះអ្នកខ្វះអ្វីខ្លះ? ព្រះយេស៊ូវប្រទានរបស់ល្អដល់យើង។ ព្រះយេស៊ូវបំពេញចិត្តយើងដោយសេចក្ដីស្រឡាញ់របស់ទ្រង់ និងជីវិតដែលទ្រង់ប្រទានឲ្យយើង។ ព្រះយេស៊ូវជាទឹករស់ ហើយទ្រង់បំពេញចិត្តយើង។

## ៦. សំនួរពិភាក្សា

១. តើព្រះយេស៊ូវនៅឯណានៅក្នុងរឿងនេះ? *(សាម៉ារី)*

២. តើទ្រង់កំពុងមានបន្ទូលជាមួយអ្នកណា? *(ស្ត្រីសាសន៍សាម៉ារីម្នាក់)*

៣. តើព្រះអង្គសុំនាងឲ្យអ្វីទៅព្រះអង្គ? *(ទឹកខ្លះ)*

៤. តើព្រះអង្គមានបន្ទូលថាទ្រង់អាចផ្ដល់ឱ្យនាងអ្វីខ្លះ? *(ទឹករស់)*

៥. តើទឹករស់ជាអ្វី? *(ព្រះយេស៊ូវគឺជាអ្នកដែលអាចបំពេញតម្រូវការទាំងអស់របស់យើង)*

## ៧. ល្បែងកំសាន្ត «ប្រៃ ឬផ្អែម»




សម្ភារៈដែលត្រូវការ៖ កែវ២ ទឹក អំបិល និងស្ករ

១. ចែកកុមារជាពីរក្រុម

២. ចាក់ទឹកចូលក្នុងកែវពីរ ដោយកែវមួយដាក់អំបិល ហើយនៅក្នុងកែវមួយទៀតដាក់ស្ករ

៣. ឲ្យកុមារម្នាក់មកពីក្រុមនីមួយៗ ហើយគ្រូនឹងសួរកុមារ ឲ្យជ្រើសរើសកែវណាមួយ បើគ្រូឲ្យរើសយកទឹកស្ករសិស្សត្រូវចង្អុលកែវដែលមានទឹកស្ករបើគ្រូឲ្យរើសទឹកអំបិលសិស្សត្រូវចង្អុលកែវទឹកអំបិល

។បើសិនជាកុមារជ្រើសរើសត្រូវតាមអ្វីដែលគ្រូប្រាប់អោយរើសក្រុមពួកគេនឹងទទួលបាន ១ពិន្ទុ




៤. គ្រូត្រូវប្តូរទីតាំងរបស់កែវទាំងពីរ សម្រាប់អ្នកលេងបន្ទាប់

៥. បន្តលេងល្បែងនេះរហូតដល់កុមារគ្រប់គ្នាបានលេង។

៦ សូមពន្យល់ដល់កុមារថា ព្រះយេស៊ូវគឺជាទឹករស់ ហើយទ្រង់គឺតែងតែផ្តល់របស់ល្អឲ្យយើង ដើម្បីបំពេញនូវសេចក្តីត្រូវការរបស់យើង។

**៨. ខគម្ពីរចងចាំ**

**យ៉ូហាន ៤៖១៤** *"តែអ្នកណាដែលផឹកទឹកខ្ញុំឲ្យ នោះនឹងមិនស្រេកទៀតឡើយ"*

**៩. ហត្ថកម្ម** **«ទឹករស់»**



សម្ភារៈដែលត្រូវការ៖ បោះពុម្ពក្រដាសហត្ថកម្ម កន្ត្រៃ កាវ កូល័រផាត់ពណ៌

១. ផាត់ពណ៌អណ្តូងដែលនៅលើក្រដាសហត្ថកម្ម

២. កាត់អណ្តូងនិងដំបូលដែលមានខគម្ពីរចងចាំ

៣. បត់អណ្តូងហើយបិតកាវដូច្នេះរូបអាចឈរដោយខ្លួនឯងបាន។

៤. បិតកាវដំបូលនៅលើគេ។

៥. នៅពេលពួកគេអានខគម្ពីរនៃការចងចាំជាមួយគ្នា សូមរំឭកកុមារថា ព្រះយេស៊ូវជាទឹករស់ ។

**១០. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ ( សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន )**
ទំនាក់ទំនងរបស់អ្នកជាមួយព្រះយេស៊ូវ គឺជាទឹករស់របស់អ្នក។ ពេលអ្នករីកចម្រើនក្នុងចំណងមិត្តភាពរបស់អ្នកជាមួយព្រះយេស៊ូវ តាមរយៈការអធិស្ឋាន និងពេលវេលានៅក្នុងព្រះគម្ពីរ អ្នកនឹងរកឃើញភាពស្រស់ស្រាយ—សូម្បីតែក្នុងគ្រាលំបាកក៏ដោយ។ ស្ត្រីសាសន៍សាម៉ារីបានធ្វើជាគន្លិះមួយដើម្បីប្រាប់អ្នករាល់គ្នាថានាងស្គាល់អំពីព្រះយេស៊ូវ។ នាងបានរកឃើញ«ទឹករស់» ហើយនាងចង់ឲ្យមនុស្សជាទីស្រឡាញ់ទាំងអស់«ភ្លក់»នូវអ្វីដែលជាចំណងមិត្តភាពជាមួយនឹងព្រះយេស៊ូវមានលក្ខណៈបែបណា។ តើអ្នកកំពុងចែករំលែកទឹករស់ជាមួយអ្នកណា? សូមព្រះប្រទានឲ្យអ្នកនូវឈ្មោះមនុស្សពីរនាក់ដែលអ្នកអាចចែករំលែកពីព្រះយេស៊ូវទៅកាន់ពួកគេបាន។





**យ៉ូហាន ៤៖១៤**

*"តែអ្នកណាដែលផឹកទឹកខ្ញុំ
ឲ្យនោះនឹងមិនស្រេកទៀត
ឡើយ។"*